# សិក្ខាសាលា ស្តីពីការទទួលបានហិរញ្ញប្បទានពាណិជ្ជកម្ម សំរាប់សហគ្រាសធុនតូច និងមធ្យម ការឆ្លើយតបរបស់កម្ពុជា រយៈពេលខ្លី ចំពោះវិបត្តិសេដ្ឋកិច្ចសកលលោក

**(Workshop on Access to finance for SMEs Cambodia's Short Term Responses to Global Economic Crisis)**

សិក្ខាសាលា ស្តីពីការទទួលបាន ហិរញ្ញប្បទានពាណិជ្ជកម្ម សំរាប់សហគ្រាសធុនតូច និងមធ្យម ការឆ្លើយតបរបស់កម្ពុជា រយៈពេលខ្លី ចំពោះវិបត្តិសេដ្ឋកិច្ចសកលលោក សហការរៀបចំដោយក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ UNDP និងមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) ត្រូវបានប្រារព្ធធ្វើឡើង នៅព្រឹកថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ នៅសណ្ឋាគារ កាំបូឌីយ៉ាណា ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម លោកជំទាវ **តាល់ ណៃអ៊ឹម** អគ្គទេសាភិបាលរងធនាគារជាតិ នៃកម្ពុជា, ឯកឧត្តម **រស់ សីលវា** អគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លោក **សុក ស៊ីផាន់ណា** នាយកផ្នែកជាដៃគូរ និងប្រភពផ្គត់ផ្គង់របស់មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ ITC លោក Jo Scheuer នាយកប្រចាំប្រទេស នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងដោយមានការចូលរួមពីឯកឧត្តម-លោកជំទាវ អស់លោក-លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្រោមឱវាទក្រសួងពាណិជ្ជកម្ម ក្រសួង-ស្ថាប័នពាក់ព័ន្ធ តំណាងសហគ្រិនធុនតូច និងមធ្យម តំណាងអ្នកគ្រប់គ្រងធនាគារនៃប្រទេសមួយចំនួន និងតំណាងអង្គការអន្តរជាតិ ជាច្រើនរូបទៀត ។

គោលបំណងនៃអង្គសិក្ខាសាលា គឺដើម្បីពិភាក្សាផ្លាស់ប្តូរបទពិសោធន៍ និងបង្ហាញពីវិធីសាស្ត្រ នៃការឆ្លើយតបរបស់កម្ពុជា ក្នុងរយៈពេលខ្លី ចំពោះវិបត្តិសេដ្ឋកិច្ចសាកលលោក ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍សហគ្រាសធន់តូច និង មធ្យម ជាពិសេសការផ្តល់ឱកាសឱ្យកាន់តែទូលំទូលាយ សំរាប់ឱ្យសហគ្រាសធនតូច និងមធ្យម មានលទ្ធភាពចូលទៅកាន់សេវាហិរញ្ញវត្ថុកាន់តែច្រើនឡើង។ ក្នុងនោះក៏នឹងពិភាក្សាបង្ហាញនីតិវិធី និងការគ្រប់គ្រងឥណទាន ពីតំណាង ធនាគារនៃប្រទេសមួយចំនួនដូចជាៈ ធនាគារប្រទេសឥណ្ឌា-ជប៉ុន ហ្វីលីពីន សំរាប់ជាបទពិសោធន៍ដល់ការបង្កើតធនាគារ អាហ៊ាណ នីហរ័ណ (Exim Bank) ជាលើកដំបូង ដែលជាប្រភពទ្រទ្រង់អាជីវកម្ម ខ្នាតតូច និងមធ្យម នៅកម្ពុជា ។

មានប្រសាសន៍បើកអង្គសិក្ខាសាលា នាឱកាសនោះ ឯកឧត្តមបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានសំដែងនូវទឹកចិត្តរីករាយ ចំពោះការអញ្ជើញចូលរួមជាសហប្រធាននៃអង្គសិក្ខាសាលា ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិ នៃកម្ពុជា ដោយមានការចូលរួមពីវាគ្មិនសំខាន់ៗ ជាលក្ខណៈអន្តរជាតិដែលនឹងជួយឱ្យអង្គសិក្ខាសាលានេះ ទទួលបាននូវការពិភាក្សា ផ្លាស់ប្តូរយោបល់ និងបង្ហាញបទពិសោធន៍ល្អៗ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបន្តថាៈ ក្នុងបរិបទនៃវិបត្តិសេដ្ឋកិច្ចសាកល ការវិនិយោគធំៗ មានការថយចុះ គឺមានតែអាជីវកម្ម ខ្នាតតូច និងមធ្យមប៉ុណ្ណោះទេ ដែលនៅមានតួនាទីសំខាន់ ក្នុងការលើកកំពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ច បង្កើតចំណូល និងទីផ្សារ ការងារ ។រាជរដ្ឋាភិបាលកម្ពុជា បានខិតខំជួយពង្រឹងដល់អាជីវកម្មទាំងនោះ តាមរយៈការដាក់ចេញ

នូវគោលនយោបាយ ជាបន្តបន្ទាប់ ដោយមានការផ្តល់ប្រភពហិរញ្ញប្បទាន រយៈពេលវែង និងមធ្យមផងដែរ ។ អ្នកជំនាញការនានាបានយល់ ឃើញដូចគ្នាថា: ភាគច្រើន នៃ SMEs របស់កម្ពុជា ត្រូវទទួលរងដោយសារការខ្វះកំចីឥណទានពីធនាគារ ដែលមានអត្រា ការប្រាក់ខ្ពស់ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានបញ្ជាក់ថា: តាមរយៈការស្រាវជ្រាវយើងឃើញថា: អាជីវកម្មខ្នាតតូច និងមធ្យម នៅកម្ពុជា មានចំនួន៩៣% ដែល ៧១% គឺជាសហគ្រាសខ្នាតតូចបំផុត (Micro-Enterprises) ដែល មានកម្មករធ្វើការតិចជាង១០នាក់។ ក្នុងនោះ ៦០% នៃ SMEs ត្រូវបានគ្រប់គ្រងដោយស្ត្រី និង៨០% មិនធ្លាប់បាន ទទួលកំចីពីធនាគារឡើយ ។ ទោះជាយ៉ាងណា មិនមែនជាដំណោះស្រាយដែលមានភាពងាយស្រួលឡើយ នៅពេលដែល មានរបាំងជាច្រើនកំពុងស្ថិតនៅ ដូចជា កង្វះភាពជាម្ចាស់សហគ្រិន កង្វះជំនាញគ្រប់គ្រង និងហិរញ្ញវត្ថុ កង្វះព័ត៌មានចូលទីផ្សារ ភាពទន់ខ្សោយ នៃហេដ្ឋារចនាសម្ព័ន្ធ ដែលធ្វើឱ្យ SMEs នៅកម្ពុជា មានដំណើរយឺតជាងប្រទេសមួយ ចំនួនក្នុងតំបន់ដូចគ្នា ។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានបញ្ជាក់បន្ថែមថា:កិច្ចការជួយ SMEs នេះ កម្ពុជាមានដៃគូរអភិវឌ្ឍន៍មួយចំនួន សំរាប់ប្រតិបត្តិការ គឺអង្គការ UNDP ជួយផ្នែកជំនួយបច្ចេកទេសអង្គការ ITC ទទួលបន្ទុកផ្នែកប្រតិបត្តិការសកម្មភាព និងភ្នាក់ងារអភិវឌ្ឍន៍នៃប្រទេសបារាំង (AFD) ជាអ្នកផ្តល់មូលនិធិកំចីតាមរយៈធនាគារ ដែលបានចូលរួម ។ នេះជាគំនិតផ្តួចផ្តើមដ៏ប្រសើរពីដៃគូរអភិវឌ្ឍន៍ ដែលនឹងត្រូវបានធ្វើបទបង្ហាញ នៅក្នុងសន្និសីទ ស្តីពីជំនួយសំរាប់ពាណិជ្ជកម្ម នៅខេត្ត សៀមរាប នាថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩ ខាងមុខនេះ ដែលសហការរៀបចំដោយ ធនាគារអភិវឌ្ឍន៍អាស៊ី ADB អង្គការពាណិជ្ជកម្មពិភពលោក WTO និងក្រសួងពាណិជ្ជកម្មកម្ពុជា ។

ក្រសួងពាណិជ្ជកម្ម សង្ឃឹមការគាំទ្រយ៉ាងមុតមាំ ពីអង្គការ UNDP និងដៃគូរអភិវឌ្ឍន៍ដទៃទៀត ដើម្បីទទួលបាននូវប្រតិបត្តិការទាន់ពេលវេលា ក្នុងការជួយ SMEs នៅកម្ពុជា ដែលទាក់ទងជាចាំបាច់លើវិស័យកសិកម្ម និងកសិ-ពាណិជ្ជកម្ម សំរាប់រដូវប្រមូលផលក្នុងឆ្នាំ២០១០ ខាងមុខ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក៏បានសំដែងនូវជំនឿថា: កិច្ចប្រជុំនេះ យើងនឹងទទួលបានការពិភាក្សាប្រកបដោយផ្លែផ្កា សំរាប់ជួយអភិវឌ្ឍន៍អាជីវកម្មខ្នាតតូច និងមធ្យម បង្កើនការនាំចេញពិសេស វិស័យធនាគារនឹងដើរតួសំខាន់ជាមួយ ដៃគូរអភិវឌ្ឍន៍កម្ពុជា ក្នុងការផ្តល់ប្រាក់កំចី សំរាប់រួមចំណែកដល់ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ នៅកម្ពុជា ។